**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**

# សេចក្តីជូនដំណឹង

## ស្តីពី

## លទ្ធផលនៃការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះ ក្នុងអំឡុងកូវីដ-១៩ សម្រាប់ខែមិថុនា

កាលពីថ្ងៃទី២៤ ខែមិថុនា ឆ្នាំ២០២០ សម្តេចតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា បានប្រកាសដាក់ឱ្យអនុវត្តជាផ្លូវការនូវកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ ហើយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា បានចាប់ផ្តើមដំណើរអនុវត្តកម្មវិធីនៅថ្ងៃទី២៥ ខែមិថុនា ឆ្នាំ២០២០។

គិតមកត្រឹមថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០ វេលាម៉ោង ១៨:០០ ការបើកផ្តល់សម្រាប់ខែមិថុនា ឆ្នាំ២០២០ ត្រូវបានបញ្ចប់ ដែលសម្រាប់ការអនុវត្តការបើកផ្តល់ខែមិថុនានេះ ចំពោះគ្រួសារក្រីក្រ ដែលបានមកផ្ទៀងផ្ទាត់ទទួលប្រាក់ឧបត្ថម្ភពីកម្មវិធីចំនួន ៥៣០ ៨៣៨ គ្រួសារ គិតជាសមាជិកមានចំនួន ២ ១៥៣ ១១៤ នាក់ ដែលក្នុងនោះកម្រិតក្រីក្រ១ មានចំនួន ១៩៨ ៦៣១ គ្រួសារ ( សមាជិក ៧៥៨ ៩៨១នាក់) និងកម្រិតក្រីក្រ២ចំនួន ៣៣២ ២០៧គ្រួសារ ( សមាជិក ១ ៣៩៤ ១៣៣ នាក់) ដោយបានចំណាយកញ្ចប់ថវិការបស់រាជរដ្ឋាភិបាលអស់ទឹកប្រាក់សរុបចំនួន ៩៤ ៥៥១ ៨៧៦ ០០០ រៀល (កៅសិបបួនប៊ីលាន ប្រាំរយហាសិបមួយលាន ប្រាំបីរយចិតសិបប្រាំមួយពាន់រៀលគត់ ) ។

សម្រាប់ការបើកប្រាក់នៅក្នុងខែកក្កដានេះត្រូវអនុវត្តដូចខាងក្រោម៖

- ចំពោះគ្រួសារដែលបានផ្ទៀងផ្ទាត់នៅខែមិថុនារួចហើយ សូមអញ្ជើញទៅបើកនៅតាមបញ្ជរវីងណាមួយ ដោយមិនតម្រូវឱ្យមកសាលាឃុំ សង្កាត់សាជាថ្មីទៀតទេ។
- ចំពោះគ្រួសារក្រីក្រ និងងាយរងគ្រោះ ដែលមានប័ណ្ណសមធម៌មានសុពលភាព ហើយមិនទាន់បានផ្ទៀងផ្ទាត់នៅក្នុងខែមិថុនា និងគ្រួសារក្រីក្រ ដែលទើបទទួលបានប័ណ្ណសមធម៌ថ្មី សូមអញ្ជើញទៅផ្ទៀងផ្ទាត់នៅ សាលាឃុំ សង្កាត់ ណាមួយ ដើម្បីទទួលបានការឧបត្ថម្ភសម្រាប់ខែកក្កដា ដែលការបើកផ្តល់ខែកក្កដាចាប់ផ្តើមពីថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០២០ តទៅ ដែលការបើកផ្តល់នេះមានរយៈពេល ៣០ថ្ងៃ។

ជាថ្មីម្តងទៀត ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ក្រសួងផែនការ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិគាំពារសង្គម រដ្ឋបាលរាជធានី ខេត្ត និងស្ថាប័នពាក់ព័ន្ធទាំងអស់ ដែលបានចូលរួមយ៉ាងសកម្មក្នុងការគាំទ្រ និងជំរុញការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩

Generated by CamScanner

ឱ្យដំណើរការទៅដោយរលូន និងទទួលបានការសាទរយ៉ាងខ្លាំងពីគ្រប់មជ្ឈដ្ឋានជាតិ និងអន្តរជាតិ ពិសេស ប្រជាជនក្រីក្រ ដែលជាក្រុមជនងាយរងគ្រោះ និងកំពុងប្រឈមយ៉ាងខ្លាំងពីឥទ្ធិពលនៃជំងឺកូវីដ-១៩ ។

អាស្រ័យដូចបានជម្រាបជូនខាងលើ សូម សាធារណៈជន និងស្ថាប័នពាក់ព័ន្ធ ជាពិសេស គ្រួសារក្រីក្រ និងងាយរងគ្រោះ ទាំងអស់មេត្តាជ្រាប និងបន្តសហការអនុវត្ត ដើម្បីឱ្យកម្មវិធីឧបត្ថម្ភសាច់ប្រាក់ជូនគ្រួសារក្រីក្រ និងងាយរងគ្រោះក្នុងអំឡុងពេលប្រយុទ្ធនឹងជំងឺកូវីដ-១៩ បន្តដំណើរការដោយរលូន និងទទួលបានជោគជ័យបន្តទៀត ស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលក្នុងការផ្តល់ការអន្តរាគមន៍ជំនួយសង្គម ដល់ប្រជាជន ពិសេស គ្រួសារក្រីក្រ និងងាយរងគ្រោះ ដោយមិនទុកឱ្យប្រជាជនណាម្នាក់ចោល ហើយមិនមានការយកចិត្តទុក ដាក់ពីរដ្ឋនោះឡើយ ។

ថ្ងៃសុក្រ ៤កើត ខែស្រាពណ៍ ឆ្នាំជូត ទោស័ក ពុទ្ធសករាជ ២៥៦៤

រាជធានីភ្នំពេញ ថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០២០